អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**អង្គភាពគាំពារជនរងគ្រោះ**
Victims Support Section
Section d'appui aux victimes

ភ្នំពេញ ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២

# សេចក្តីប្រកាសព័ត៌មាន

## អង្គភាពគាំពារជនរងគ្រោះនឹងរៀបចំវេទិកាថ្នាក់តំបន់លើកទី៣ ឆ្នាំ២០១២ នៅក្រុងសៀមរាប ខេត្តសៀមរាប សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០២

អង្គភាពគាំពារជនរងគ្រោះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នឹងរៀបចំវេទិកាថ្នាក់តំបន់លើកទី៣ ក្នុងឆ្នាំ២០១២នេះ នៅខេត្តសៀមរាប សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ចំនួន ២០០ នាក់ ក្នុងចំណោម៣៨៦៤នាក់ នៃសំណុំរឿង០០២។ វេទិកាថ្នាក់តំបន់នេះនឹងធ្វើនៅ ***សណ្ឋាគារ អលេសិនអង្គរប៉ារ៉ាឌី នាថ្ងៃសៅរ៍ ទី២៥ ខែសីហា ឆ្នាំ២០១២ វេលាម៉ោង ៨:០០ព្រឹក ដល់ ម៉ោង ៤:០០ រសៀល។*** *(អត្តសញ្ញាណរបស់ដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវបានរក្សាជាសម្ងាត់)* ។

វេទិកាថ្នាក់តំបន់នេះមានគោលបំណង (១)ផ្តល់ព័ត៌មានថ្មីៗអំពីការវិវឌ្ឍរបស់ អ.វ.ត.ក ទាក់ទងនឹងសំណុំរឿង០០២ ដល់ដើមបណ្តឹងរដ្ឋប្បវេណី (២) ដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណីទទួលបានការពន្យល់ពីមេធាវីរបស់ខ្លួននូវដំណើការនៃការបំបែកនីតិវីធីសំណុំរឿង ០០២ ដែលកំពុងជម្រះក្តីជាផ្នែកតូចៗដាច់ពីគ្នានិង (៣) ដើម្បីឲ្យដើមបណ្តឹង រដ្ឋប្បវេណីទាំងនោះប្រើប្រាស់សិទ្ធិរបស់ខ្លួន។

ដើមបណ្តឹងរដ្ឋប្បវេណីទាំង ២០០នាក់ ធ្វើដំណើរមកពី ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាបនេះស្ថិតក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីទាំង ៣ ៨៦៤នាក់ ដែលមិនធ្លាប់បានចូលរួមស្តាប់សវនាការ នៃសំណុំរឿង០០២ក្នុងឆមាសទី១ ឆ្នាំ២០១២ នេះទេ។ វេទិកាថ្នាក់តំបន់នេះនឹងផ្តល់ឱកាសពិសេសសម្រាប់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងដើមបណ្តឹងរដ្ឋប្បវេណីទាំង ២០០ នាក់ បានជួបគ្នាដើម្បីពិភាក្សាពន្យល់អំពីការវិវឌ្ឍរបស់សំណុំរឿង០០២ និងស្វែងយល់អំពីដំណាក់កាលដែលដើមបណ្តឹងរដ្ឋប្បវេណីទទួលរងគ្រោះដោយឧក្រិដ្ឋកម្មផ្សេងៗគ្នា ត្រូវរួមនៅក្នុងដំណើរការកាត់សេចក្តីជាផ្នែកៗដាច់ពីគ្នានេះ។

អង្គភាពគាំពារជនរងគ្រោះមានផែនការរៀបចំវេទិកាថ្នាក់តំបន់ចំនួន ៨ ក្នុងឆ្នាំ ២០១២-២០១៣ ស្ថិតក្នុងគម្រោង "ការចូលរួមរបស់ជនរងគ្រោះប្រកបដោយអត្ថន័យក្នុងដំណើការនីតិវិធី អ.វ.ត.ក។ កាលពីឆ្នាំ២០០៩- ២០១១ អង្គភាពគាំពារជនរងគ្រោះបានរៀបចំវេទិកាថ្នាក់តំបន់ចំនួន១៤ ស្ថិតក្នុងក្របខ័ណ្ឌគម្រោង "ការធ្វើឲ្យប្រសើរឡើងដល់ការចូលរួមរបស់ជនរងគ្រោះក្នុងដំណើការនីតិវិធី អ.វ.ត.ក"។

---

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖
អ៊ឹម សុភា, ប្រធានកម្មវិធីផ្សព្វផ្សាយនៃអង្គភាពគាំពារជនរងគ្រោះ
ទូរស័ព្ទចល័ត: ០៧៧ ៧៧៧ ៣៦៧, អ៊ីម៉ែល: im.sophea@eccc.gov.kh